# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសជឿនលឿន នៅលើពិភពលោក និងប្រទេសនៅអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា។

នៅត្រីមាសទី៣ ឆ្នាំ២០១២ ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក នៅមានលក្ខណៈផុយស្រួយ និងមិនទាន់ប្រាកដប្រជា ព្រោះប្រទេសចម្បងៗនៅមានសញ្ញាធ្លាក់កំណើនសេដ្ឋកិច្ច ជាពិសេសនៅតំបន់អាស៊ី និងអឺរ៉ុប។

នៅត្រីមាសទី៣ នេះ ផសស ពិត នៅឥណ្ឌូនេស៊ី ធ្លាក់ចុះបន្តិចពី មកត្រឹម ៦,២% ធៀបនឹង ៦,៤% នៅខែមុន និង ៦,៥% កាលពីមួយឆ្នាំមុន។ ផសស នៅម៉ាឡេស៊ី ធ្លាក់ចុះបើធៀបនឹងមួយឆ្នាំមុន មកត្រឹម ៥,២%។ ផសស នៅសិង្ហបុរី ធ្លាក់ចុះពី ៥,៩% កាលពីមួយឆ្នាំមុន មកត្រឹម ០,៣% ដែលអត្រាទាបបំផុតគិតចាប់ពីឆ្នាំ២០១០ មក។ ទោះបីមានកំណើនយឺតជាងមុនក្តី ចិននៅតែស្ថិតក្នុងចំណោមប្រទេសមានសេដ្ឋកិច្ចកើនលឿនបំផុត ដោយមានកំណើន ផសស ប្រមាណ ៧,៤% នៅត្រីមាសទី៣ គឺធ្លាក់ចុះបន្តិច បើធៀបនឹងអត្រា ៧,៥% កាលពីត្រីមាសមុន។ ការនាំចេញរបស់ចិន មានដំណើរការល្អដោយមានកំណើន ២០,៣% នៅឆ្នាំ២០១១ និង រួមចំណែក ២៨,៦% នៃ ផសស យោងតាមស្ថិតិចេញផ្សាយដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ទោះបីជាជម្លោះដែនដីទាក់ទងនឹងកោះតូចៗមួយចំនួន រវាងចិន នឹងជប៉ុន និងរវាងចិន នឹងប្រទេសបីបួនទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ បានបង្កើតភាពតានតឹងខាងនយោបាយ និងក្នុងកម្រិតណាមួយខាងយោធាដែរក្តី ក៏វាមិនមានផលប៉ះពាល់ធំដុំអ្វីទៅលើពាណិជ្ជកម្មរបស់ចិនជាមួយបណ្តាប្រទេសមានជម្លោះ និងលើវិនិយោគទុនពីប្រទេសទាំងនោះទេ។ ទោះបីជាវិនិយោគិនជប៉ុននៅប្រទេសចិន កំពុងរកមើលឱកាសវិនិយោគក្នុងតំបន់ដទៃក្តី ក៏ចំនួនវិនិយោគិនដែលចាកចេញ មិនទាន់ធ្វើឲ្យខូចខាតដល់កំណើនទេ ហើយកិច្ចប្រឹងប្រែងដោះស្រាយជម្លោះតាមផ្លូវសន្តិវិធី និងការទូត ប្រហែលសម្រេចបានជោគជ័យ។ កំណើន ផសស ពិត នៅហុងកុង រួមចុះមកត្រឹម ១,៣% ធៀបនឹង ៣,៦% នៅត្រីមាសមុន ហើយនៅកូរ៉េខាងត្បូង វាធ្លាក់ចុះពី ២,៤% មកត្រឹម ១,៥%។

កិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ចនៅតំបន់អឺរ៉ូ មិនទាន់បានជោគជ័យល្អទេ។ ទោះបីជាមានការផ្តល់កញ្ចប់ជំនួយទ្រទ្រង់ហិរញ្ញវត្ថុទៅឲ្យប្រទេសក្រិកក្តី ក៏មានការវាយស្មានពីមជ្ឈដ្ឋានមួយចំនួនថា តំបន់អឺរ៉ូអាចត្រូវបាក់បែកខ្លះ។ នៅត្រីមាសទី៣ កំណើន ផសស នៅតំបន់អឺរ៉ូ រួមចុះដល់ -០,៦%។ សេដ្ឋកិច្ចជប៉ុនក៏មានកំណើនយឺតដែរ ក្នុងអត្រា ០,១% ធៀបនឹង ៣,៥% កាលពីត្រីមាសមុន។ សហរដ្ឋអាមេរិក បន្តមានដំណើរការល្អ បើធៀបនឹងប្រទេសមានៗដទៃទៀត ដោយទទួលបានកំណើន ២,៥% ធៀបនឹង ២,២% នៅត្រីមាសមុន។ សមិទ្ធផលនេះ សម្រេចបានក្នុងពេលកំពុងមានការវាយស្មានថា សហរដ្ឋអាមេរិកអាចធ្លាក់ទៅក្នុងវិបត្តិសេដ្ឋកិច្ចជាលើកទី២ ដោយសារការកាត់បន្ថយឱនភាពថវិកាយ៉ាងគំហុក ដែលជាលទ្ធផលគួបផ្សំគ្នានៃការតម្លើងពន្ធ និងការកាត់បន្ថយចំណាយ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ថ្លៃទំនិញប្រើប្រាស់ មិនមែនជាក្តីបារម្ភផ្នែកនយោបាយឡើយ សម្រាប់ស្ទើរគ្រប់ប្រទេស ពីព្រោះអត្រាអតិផរណាមានកម្រិតល្មមអាចគ្រប់គ្រងបាន។ រីឯប្រទេសជប៉ុន ថែមទាំងជួបប្រទះបរិត្តផរណាទៀតផង។ នៅកម្ពុជា អតិផរណា ធ្លាក់ចុះមកត្រឹម ១,៦% ធៀបនឹង ២,៩% នៅត្រីមាសមុន និង ៦,៧% នៅឆ្នាំមុន។ នៅវៀតណាម អតិផរណាបន្តធ្លាក់ចុះពី ២២,៥% នៅឆ្នាំមុន មកត្រឹម ៥,៦% ដែលជាអត្រាទាបបំផុតគិតចាប់ពីពេលចាប់ផ្តើមផ្ទុះវិបត្តិហិរញ្ញវត្ថុ។ ប្រទេសជប៉ុន បានជួបប្រទះការធ្លាក់ចុះថ្លៃទំនិញប្រើប្រាស់ជាទូទៅ ដែលដាក់សម្ពាធបង្កើនអត្រាការប្រាក់ពិត។

នៅត្រីមាសទី៣ ប្រាក់រៀល ធ្លាក់ថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារUS ប៉ុន្តែឡើងថ្លៃ ០,៩% បើធៀបនឹងមួយឆ្នាំមុន។ ប្រាក់រូពីយ៉ាឥណ្ឌូណេស៊ី ធ្លាក់ថ្លៃ ២,៣% ធៀបនឹងត្រីមាសមុន (១០% ធៀបនឹងមួយឆ្នាំមុន) ហើយប្រាក់រីងហ្គីតម៉ាឡេស៊ី ធ្លាក់ថ្លៃ ០,៣% (៣,៣%ធៀបនឹងមួយឆ្នាំមុន)។ ប្រាក់អឺរ៉ូ ធ្លាក់ថ្លៃ ៣,៩% ទល់នឹងប្រាក់ដុល្លារ (១២,៧% ធៀបនឹងមួយឆ្នាំមុន)។ នៅត្រីមាសនេះដែរ ប្រាក់យេនជប៉ុន ឡើងថ្លៃ ១,៨% ទល់នឹងប្រាក់ដុល្លារ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៣ ពោត(US No.2) ឡើងថ្លៃ ២១% (៨,០% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣២៧,១ដុល្លារ/តោន សណ្តែកសៀង(US No.1) ឡើងថ្លៃ ១៨,៨% (២៦,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ៦៤៩,៤ដុល្លារ/តោន ហើយ ប្រេងម៉ាស៊ូត(low sulphur No.2) ឡើងថ្លៃ ៤,២% (៤,៩%ធៀបនឹងមួយឆ្នាំមុន) ដល់ ០,៨២ដុល្លារ/លីត្រ។ កៅស៊ូ(SMR5) ធ្លាក់ថ្លៃ ១៦,៧% (៣៩,៤%ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៧៩៩,២ដុល្លារ/តោន ប្រេងឆៅ(OPEC spot) ធ្លាក់ថ្លៃ ០,១% (២,១% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១០៦,៦ដុល្លារ/ធុង និង សាំង ធ្លាក់ថ្លៃ ៣,៣% (៤,១% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ០,៧២ដុល្លារ/លីត្រ។ នៅត្រីមាសទី៣ អង្ករថៃ(Thai 100%B) ធ្លាក់ថ្លៃ ០,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៩៥,៧ដុល្លារ/តោន ប៉ុន្តែឡើងថ្លៃ ២,៥% ធៀបនឹងមួយឆ្នាំមុន។

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន )

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | 0.1 | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 5.4 | 6.3 | 6.1 | 4.2 | 6.9 | 6.5 | 6.5 | 6.5 | 6.5 | 6.3 | 6.4 | 6.2 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -2.4 | 4.8 | 4.6 | 4.0 | 5.8 | 5.2 | 4.7 | 5.4 | 5.2 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -4.5 | 12.0 | 8.3 | 0.9 | 5.9 | 3.6 | 1.6 | 1.9 | 0.3 |
| ថៃ | 4.8 | 4.9 | 2.6 | 3.3 | 3.8 | 3.0 | 2.6 | 3.5 | -9.0 | 0.0 | 4.2 | 3.3 |
| វៀតណាម | 8.1 | 8.5 | 6.2 | 4.7 | 7.3 | 5.4 | 5.7 | 7.2 | 6.1 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 8.2 | 9.8 | 9.7 | 9.5 | 9.1 | 8.9 | 8.1 | 7.6 | 7.4 |
| ហុងកុង | 6.6 | 6.4 | 2.4 | -3.2 | 6.2 | 7.2 | 5.1 | 4.3 | 3.0 | 4.2 | 3.6 | 1.3 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -1.0 | 4.8 | 4.2 | 3.4 | 3.4 | 3.4 | 3.0 | 2.4 | 1.5 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -3.6 | 6.9 | 6.5 | 4.9 | 3.4 | 1.9 | 0.4 | -0.2 | 1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -3.8 | 2.0 | 2.5 | 1.6 | 1.4 | 0.7 | 0.0 | -0.4 | -0.6 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -5.4 | 2.2 | -1.0 | -1.0 | 0.0 | -1.0 | 2.8 | 3.5 | 0.1 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.5 | 2.8 | 2.3 | 1.5 | 1.6 | 1.6 | 2.1 | 2.2 | 2.5 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ )

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | | 3.3 | 3.6 | 6.2 | 6.7 | 4.9 | 5.5 | 2.9 | 1.6 |
| ឥណ្ឌូណេស៊ី | 13.4 | 6.4 | 10.1 | 4.7 | 6.3 | 6.8 | 5.9 | 4.7 | 4.1 | 3.8 | 4.5 | 4.5 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 0.4 | 2.1 | 2.8 | 3.3 | 3.4 | 3.2 | 2.3 | 1.7 | 1.4 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 0.5 | 4.0 | 5.2 | 4.7 | 5.5 | 5.5 | 4.9 | 5.2 | 4.2 |
| ថៃ | 4.7 | 2.2 | 5.5 | -0.9 | 2.0 | 3.0 | 4.1 | 4.1 | 4.0 | 3.4 | 2.6 | 2.9 |
| វៀតណាម | 7.7 | 8.3 | 23.3 | 7.3 | 10.9 | 12.8 | 19.4 | 22.5 | 19.8 | 16.0 | 8.6 | 5.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.8 | 4.7 | 5.1 | 5.7 | 6.3 | 4.6 | 3.8 | 2.9 | 1.9 |
| ហុងកុង | 2.2 | 2.0 | 4.3 | -0.3 | 2.9 | 4.0 | 5.1 | 6.5 | 5.7 | 5.2 | 4.2 | 3.1 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 2.8 | 3.6 | 4.4 | 4.2 | 4.8 | 4.1 | 2.9 | 2.4 | 1.6 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | -1.1 | 1.1 | 1.3 | 1.6 | 1.3 | 1.4 | 1.3 | 1.6 | 3.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 0.4 | 2.0 | 2.5 | 2.7 | 2.7 | 2.9 | 2.7 | 2.5 | 2.5 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -1.3 | 0.1 | 0.0 | 0.3 | 0.2 | -0.3 | 0.3 | 0.2 | -0.4 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.4 | 1.3 | 2.1 | 3.5 | 3.8 | 3.3 | 2.8 | 1.9 | 1.7 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១២ ( មធ្យមភាគតាមការិយបរិច្ឆេទ )

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា ( រៀល ) | 4062.70 | 4054.20 | 4140.48 | 4187.09 | 4041.90 | 4044.89 | 4095.66 | 4071.89 | 4045.98 | 4054.26 | 4060.21 |
| ឥណ្ឌូណេស៊ី ( រូពីយ៉ា ) | 9419.00 | 9699.00 | 10413.83 | 9089.94 | 8902.02 | 8593.94 | 8625.83 | 8985.65 | 9078.63 | 9281.28 | 9490.25 |
| ម៉ាឡេស៊ី ( រីងហ្គិត ) | 3.30 | 3.30 | 3.52 | 3.22 | 3.05 | 3.02 | 3.02 | 3.15 | 3.06 | 3.11 | 3.12 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី ) | 1.51 | 1.42 | 1.45 | 1.36 | 1.28 | 1.24 | 1.23 | 1.29 | 1.26 | 1.26 | 1.25 |
| ថៃ ( បាត ) | 32.22 | 33.36 | 34.34 | 31.73 | 30.56 | 30.28 | 30.15 | 30.98 | 31.00 | 31.28 | 31.34 |
| វៀតណាម ( ដុង ) | 16,030.00 | 16,382.00 | 17,725.24 | 19200.79 | 20,273.83 | 20,693.58 | 20,699.60 | 20,997.70 | 20,971.18 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន ( យ៉ន់ ) | 8.03 | 6.94 | 6.83 | 6.76 | 6.58 | 6.50 | 6.42 | 6.36 | 6.31 | 6.33 | 6.35 |
| ហុងកុង ( ដុល្លារហុងកុង ) | 7.80 | 7.78 | 7.75 | 7.77 | 7.79 | 7.78 | 7.79 | 7.78 | 7.76 | 7.76 | 7.76 |
| កូរ៉េខាងត្បូង ( វ៉ុន ) | 929.04 | 1137.23 | 1277.76 | 1156.32 | 1120.19 | 1084.27 | 1084.90 | 1144.87 | 1131.17 | 1152.59 | 1132.85 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$ ) | 32.85 | 31.54 | 33.04 | | 29.30 | 28.86 | 29.19 | 30.26 | 29.68 | 29.62 | 29.82 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ ( អឺរ៉ូ ) | 0.70 | 0.84 | 0.72 | 0.76 | 0.73 | 0.70 | 0.71 | 0.74 | 0.76 | 0.77 | 0.80 |
| ជប៉ុន ( យ៉េន ) | 117.80 | 102.46 | 93.60 | 87.80 | 82.33 | 81.66 | 77.86 | 77.78 | 79.30 | 80.07 | 78.60 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១២ ( មធ្យមភាគតាមការិយបរិច្ឆេទ )

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - USA ( USD/តោន ) | 149.08 | 218.15 | 167.31 | 169.90 | 280.32 | 311.63 | 302.79 | 270.77 | 277.50 | 270.46 | 327.14 |
| ប្រេងឆា-អឺរ៉ុបពាយព្យ ( USD/តោន ) | 707.68 | 912.23 | 686.84 | 834.75 | 1251.00 | 1147.00 | 1079.00 | 1024.67 | 1106.67 | 1133.0 | - |
| កៅស៊ូ SMR 5 ( USD/តោន ) | 2202.30 | 2586.30 | 1884.84 | 3152.17 | 5278.03 | 4968.77 | 4617.57 | 3658.00 | 3701.17 | 3361.0 | 2799.23 |
| អង្ករ ( Thai 100%B ) - បាងកក ( USD/តោន ) | 305.36 | 615.32 | 524.47 | 456.67 | 528.25 | 514.33 | 581.3 | 610.33 | 549.00 | 600.3 | 595.67 |
| សណ្តែកសៀង ( US No. 1 ) - USA ( USD/តោន ) | 294.59 | 460.41 | 414.03 | 375.38 | 537.24 | 525.66 | 513.98 | 454.83 | 490.79 | 546.5 | 649.36 |
| ប្រេងឆៅ - OPEC spot ( USD/ធុង ) | 69.25 | 95.44 | 60.50 | 71.61 | 100.70 | 113.31 | 108.91 | 109.1 | 117.3 | 106.7 | 106.6 |
| សាំង - US Gulf Coast ( សេន/លីត្រ ) | 53.58 | 62.22 | 42.91 | 49.83 | 67.92 | 78.73 | 74.63 | 68.50 | 78.97 | 74.0 | 71.56 |
| ម៉ាស៊ូត ( ស្តាន់ដ័រតិច លេខ២ ) - US Gulf Coast ( សេន/លីត្រ ) | 55.51 | 76.20 | 43.05 | 51.62 | 72.47 | 75.72 | 77.27 | 77.31 | 83.75 | 77.8 | 81.09 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ចលនាឡើងចុះ និងភាពមិនច្បាស់លាស់ ក្នុងសេដ្ឋកិច្ចពិភពលោក នៅតែបន្តប៉ះពាល់ដល់កំណើន និងការរើបឡើងវិញ នៅប្រទេសកម្ពុជា ជាពិសេសក្នុងវិស័យជំរុញកំណើនចម្បងៗ។ ភាពតឹងតែងក្នុងការរើបឡើងវិញនៅតំបន់អឺរ៉ូ ការកាត់បន្ថយឱនភាពថវិកាយ៉ាងគំហុកនៅសហរដ្ឋអាមេរិក (fiscal cliff) និងការធ្លាក់ចុះកំណើនសេដ្ឋកិច្ចក្នុងប្រទេសចម្បងៗនៅអាស៊ី អាចជាមូលហេតុនៃការថយចុះកំណើនក្នុង សកម្មភាពសេដ្ឋកិច្ចចម្បងៗនៅកម្ពុជា នៅត្រីមាសទី៣ ឆ្នាំ២០១២។

នៅត្រីមាសទី៣ តម្លៃសរុបនៃគម្រោងវិនិយោគឯកជនដែលបានអនុម័ត កើនឡើង ៥៧,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ៨៤,៤% ធៀបនឹងមួយឆ្នាំមុន មកត្រឹម ៤២៨,៨លានដុល្លារ។ វិនិយោគខាងកសិកម្ម កើន ១០៥,៨% ធៀបនឹងត្រីមាសមុន (៣៤,៩% ធៀបនឹងមួយឆ្នាំមុន)។ វិនិយោគខាងឧស្សាហកម្ម កើន ៤៩,៤% ធៀបនឹងត្រីមាសមុនដល់ ២៥៩,៩ លានដុល្លារ ប៉ុន្តែធ្លាក់ចុះ ៨៩% ធៀបនឹងមួយឆ្នាំមុន។ នៅត្រីមាសដដែលនេះ វិនិយោគខាងសេវាកម្ម ធ្លាក់ចុះ ៨៨,៣% (៩៩,២% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២,១លានដុល្លារ ហើយគ្មានវិនិយោគខាងផ្នែកសណ្ឋាគារ និងទេសចរណ៍ទេ។ វិនិយោគខាងផ្នែកកាត់ដេរ ដែលជាប្រភពផលិតផលនាំចេញដ៏ចម្បង និងរួមចំណែក ៤១,៣% នៃវិនិយោគបានអនុម័តសរុបក្នុងវិស័យឧស្សាហកម្ម បានកើនឡើង ៩,៩% ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ២,៣% ធៀបនឹងមួយឆ្នាំមុន។ វិស័យអចលនទ្រព្យ មិនទាន់ងើបឡើងបានពេញលេញដូចមុនពេលមានវិបត្តិទេ ដោយសារតម្លៃសំណង់នៅតែបន្តឡើងចុះ។ នៅត្រីមាសទី៣ នេះ តម្លៃគម្រោងបានអនុម័តសម្រាប់ការសាងសង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះ ៧២,៥% ធៀបនឹងត្រីមាសមុន (៨២,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៨,៣លានដុល្លារ ហើយសម្រាប់ផ្ទះល្វែង វាធ្លាក់ចុះ ៧១,៩% (៣១,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៦១,៦លានដុល្លារ រីឯសម្រាប់គម្រោងសាងសង់ផ្សេងទៀត វាកើន ៩៨,៥% ធៀបនឹងត្រីមាសមុន (៨៥,៧% ធៀបនឹងមួយឆ្នាំមុន)។ ក្នុងត្រីមាសនេះដែរ ចំនួនភ្ញៀវទេសចរមកដល់កម្ពុជា បន្តនិន្នាការកើនឡើង ដោយកើន ៧,៨% (១៧,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ៨២១.000នាក់។

នៅត្រីមាសទី៣ ការនាំចេញសរុប ធ្លាក់ចុះ ១០,១% (តែកើន ៩,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៥៩៦លានដុល្លារ។ ដោយឡែក ការនាំចេញសម្លៀកបំពាក់ ធ្លាក់ចុះ ៩,៩% (កើន ៣,៤% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៣២៩លានដុល្លារ ក្នុងនេះ ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក (៤២,៦% នៃការនាំចេញសរុប) ធ្លាក់ចុះ ៩,៧% (៨,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥៦៦,៦លានដុល្លារ រីឯការនាំចេញទៅសហគមន៍អឺរ៉ុប (៣៤,៨% នៃការនាំចេញសរុប) ធ្លាក់ចុះ ៨,២% ប៉ុន្តែកើន ១៦,៤% ធៀបនឹងមួយឆ្នាំមុន ដល់ ៤៦២,៧លានដុល្លារ។ ម្យ៉ាងទៀត ការនាំចេញខាងកសិកម្ម (៥,៤% នៃការនាំចេញសរុប) ធ្លាក់ចុះ ១៥% (១៣% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៨៦,១លានដុល្លារ ក្នុងនេះការនាំចេញកៅស៊ូធ្លាក់ចុះ ០,៦% (១៧,៨% ធៀបនឹងមួយឆ្នាំមុន) ការនាំចេញឈើធ្លាក់ចុះ ៦៦,៩% (៧៤,៥% ធៀបនឹងមួយឆ្នាំមុន) ការនាំចេញត្រីធ្លាក់ចុះ ៤២,៩% (៧១,៤% ធៀបនឹងមួយឆ្នាំមុន) ហើយការនាំចេញអង្ករ ធ្លាក់ចុះ ១៥,៥% មកត្រឹម ៣១,៧លានដុល្លារ តែកើន ៤១,៥% បើធៀបនឹងមួយឆ្នាំមុន។ នៅត្រីមាសទី៣ នេះដែរ ការនាំចូលសរុប កើន ៦,៩% (៣២,៧% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០១៥លានដុល្លារ។ ការនាំចូលសាំង កើន ១,៧% (៥,៧% ធៀបនឹងមួយឆ្នាំមុន) ម៉ាស៊ូត កើន ៩,២% (១៦,៣% ធៀបនឹងមួយឆ្នាំមុន) ហើយ សម្ភារៈសំណង់ កើន ១៧% (៤២,២% ធៀបនឹងមួយឆ្នាំមុន)។

## ហិរញ្ញវត្ថុសាធារណៈ

កិច្ចប្រឹងប្រែងពង្រឹងការប្រមូលចំណូល និងកាត់បន្ថយចំណាយខ្ជះខ្ជាយរបស់រដ្ឋាភិបាល គួរបន្តមានចែងក្នុងរបៀបវារៈ។ ទោះបីថវិការដ្ឋាភិបាល តែងឡើងចុះតាមត្រីមាសក្តី ប៉ុន្តែក្នុងត្រីមាសទី៣ ឆ្នាំ២០១២ វាមាននិន្នាការល្អ បើធៀបនឹងមួយឆ្នាំមុន។ នៅត្រីមាសទី៣ ចំណូលសរុបធ្លាក់ចុះ ៧,១% ធៀបនឹងត្រីមាសមុន (កើន ២៥,៩% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៩០០,៨ពាន់លានរៀល ក្នុងនេះ ចំណូលចរន្ត ធ្លាក់ចុះ ៦,៩% (កើន ២០% ធៀបនឹងមួយឆ្នាំមុន) ហើយ ចំណូលពន្ធ ធ្លាក់ចុះ ៩,៤% តែកើន ១៨,៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៥៦០,៧ពាន់លានរៀល។ ក្នុងត្រីមាសនោះដែរ ចំណាយសរុបកើន ២១,៧% (២៧,៧% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៩៥១,៣ ពាន់លានរៀល។ ការដែលកម្ពុជាទទួលវេនធ្វើជាប្រធានអាស៊ានក៏បានរួមចំណែកមួយផ្នែកក្នុង កំណើនចំណាយនេះដែរ។ ចំណាយមូលធន កើន ៦៦,៨% ធៀបនឹងត្រីមាសមុន (៤៩,១% ធៀបនឹងមួយឆ្នាំមុន) ដែលជាសញ្ញាបង្ហាញថា រដ្ឋាភិបាលបានចំណាយកាន់តែច្រើនទៅលើការសាង់សង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ។ ចំណាយចរន្ត កើន ២,៨% ធៀបនឹងត្រីមាសមុន (១៦,៤% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៧៥៦,៧ពាន់លានរៀល ចំណាយលើបៀវត្សរ៍ ធ្លាក់ចុះ ៩,៣% (កើន ៤,៤% ធៀបនឹងមួយឆ្នាំមុន) ចំណាយលើឧបត្ថម្ភធន និង ជំនួយសង្គមកិច្ច ធ្លាក់ចុះ ១០,២% (៤២,៩% ធៀបនឹងមួយឆ្នាំមុន)។

---

១ អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## អតិផរណា និងអត្រាប្តូរប្រាក់

អតិផរណា ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ នៅត្រីមាសទី៣ ថ្លៃទំនិញជាទូទៅនៅភ្នំពេញ កើន ១,៦% ធៀបនឹងមួយឆ្នាំមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ១,៣% ហើយថ្លៃដឹកជញ្ជូន កើន ១,១%។ ប្រាក់រៀល ធ្លាក់ថ្លៃ ០,២% ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ០,៩% ធៀបនឹងមួយឆ្នាំមុន។ មាស ឡើងថ្លៃ ២,០% ធៀបនឹងត្រីមាសមុន (ធ្លាក់ថ្លៃ ៣,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៩៨,៣ដុល្លារ/ជី ហើយម៉ាស៊ូត ឡើងថ្លៃ ១១,៨% (១,២% ធៀបនឹងមួយឆ្នាំមុន)។ សាំង ធ្លាក់ថ្លៃ ១,១% ប៉ុន្តែឡើងថ្លៃ ០,១% ធៀបនឹងមួយឆ្នាំមុន។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី២ ទ្រព្យសកម្មបរទេសសុទ្ធ កើន ០,៤% ធៀបនឹងត្រីមាសមុន (៣,៥% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៨.៧២៩,៦ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ២៧,៥% (១០២,៧% ធៀបនឹងមួយឆ្នាំមុន) ដល់ ៧៩២២,៣ពាន់លានរៀល។ រូបិយវត្ថុទូទៅ កើន ២១,១% ធៀបនឹងមួយឆ្នាំមុន ហើយរូបិយវត្ថុ កើន ៩,៤% រីឯ រូបិយវត្ថុផ្សេងៗ កើន ២៣,៤%។

## ស្ថានភាពក្រីក្រ

អង្កេតប្រចាំត្រីមាសរបស់វិទ្យាស្ថាន CDRI លើពលករងាយរងគ្រោះ ធ្វើឡើងនៅថ្ងៃទី ៦-២១ វិច្ឆិកា ២០១២ បង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ ក្រុមកម្មករងាយរងគ្រោះភាគច្រើន កើនឡើង បើធៀបនឹងពេលដូចគ្នាក្នុងឆ្នាំមុន។ ក្រុមពលករទាំងនោះ រួមមាន អ្នកជាក់ស៊ីក្លូ អ្នកលីសែង អ្នកលក់បន្លែតូចតាច អ្នកបំរើភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់។ ក្នុងចំណោមនោះ អ្នកលក់បន្លែតូចតាច មានចំណូលកើនឡើងច្រើនជាងគេ។

ប្រាក់ចំណូលមធ្យមប្រចាំថ្ងៃពិតរបស់អ្នកជាក់ស៊ីក្លូ កើន ១២,៥% ដល់ ១០.៤៥៤រៀល ក្នុងខែវិច្ឆិកា ២០១២ ហើយចំណាយប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគាត់ គឺ ៥៤៨១,៤រៀល។ ក្នុងចំណោមអ្នកជាក់ស៊ីក្លូឆ្លើយសម្ភាសន៍ មាន ៩០% ត្រូវជួលស៊ីក្លូមករកចិញ្ចឹមជីវិត និង ១១,៤% ជាសមាជិកនៃសមាគមអ្នកជាក់ស៊ីក្លូ។

ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃរបស់អ្នកលីសែង កើន ៩,៥% ធៀបនឹងពេលដូចគ្នាក្នុងឆ្នាំ២០១១ ដល់ ១២.៥៧៤រៀល/ថ្ងៃ ហើយចំណាយជាមធ្យម ធ្លាក់ចុះ ០,៧% ពី ៧២៣៨,៦រៀល/ថ្ងៃ មកត្រឹម ៧១៨៤,៨រៀល/ថ្ងៃ។ ក្នុងចំណោមពួកគាត់ មាន ៩៥% ប្រាប់ថា គាត់ស្នាក់នៅផ្ទះជួល ដែលមានអ្នកជួលរួមគ្នាជាមធ្យម ៧នាក់។ ម្យ៉ាងទៀត ៩៧,៥% នៃអ្នកលីសែងបានឆ្លើយសម្ភាសន៍ ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។

ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នករត់ម៉ូតូឌុប កើន ១,០% ពី ១២.២៥៦រៀល ដល់ ១៣.០៤២រៀល។ ជាមធ្យម ពួកគាត់ប្រកបរបរនេះបាន ៣ឆ្នាំ មកហើយ ដោយត្រូវរត់ម៉ូតូ ៨,៤ម៉ោង/ថ្ងៃ។ ក្នុងចំណោមអ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ មាន ២៥% ជំពាក់បំណុលគេក្នុងចំនួនជាមធ្យម ៧១៣.៩២០រៀល និង មាន ៩៥% បញ្ជាក់ថា ការឡើងថ្លៃម្ហូបអាហារ បានប៉ះពាល់រូបគាត់ដោយផ្ទាល់ខ្លាំងបំផុត។

ចំណូលជាមធ្យមប្រចាំថ្ងៃរបស់ កម្មករសំណង់គ្មានជំនាញ កើន ១៥,៤% ពី ៩៨៥៩រៀល/ថ្ងៃ ដល់ ១១.៣៧៥រៀល/ថ្ងៃ រីឯ ចំណូលរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ៤,៤% ពីកម្រិត ១៤.៩៣០រៀល/ថ្ងៃ។ មានតែ ៥% នៃកម្មករសំណង់មានជំនាញប៉ុណ្ណោះ ដែលបានដឹងពីសមាគមកម្មករសំណង់ ហើយគ្មានពួកគាត់ណាម្នាក់ បានចូលជាសមាជិកសមាគមនោះទេ។

ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាច កើន ៤៩% ដល់ ១០.៥៤២រៀល នៅខែវិច្ឆិកា ២០១២។ អ្នកលក់បន្លែឆ្លើយសម្ភាសន៍ សុទ្ធតែជាមេគ្រួសារគ្រប់គ្នា ហើយគ្រួសារគាត់មានសមាជិកជាមធ្យម ៥នាក់។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៩,៩% ដល់ ៥០០០រៀល។ ក្នុងចំណោមពលករឆ្លើយសម្ភាសន៍ មាន ៣៥% គ្មានដីទេ ៦០% មានដី ១ហិកតា ហើយ ៥% មានដី ៣ហិកតា។ អ្នកស៊ីឈ្នួលធ្វើស្រែ មានចំណាយសរុបប្រចាំថ្ងៃទាបបំផុត បើធៀបនឹងក្រុមដទៃទៀត គឺត្រឹម ២៣៨៨រៀល/ថ្ងៃប៉ុណ្ណោះ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៩,៣% នៅខែវិច្ឆិកា បើធៀបនឹងឆ្នាំមុន។ ចំណាយសរុបប្រចាំថ្ងៃរបស់ពួកគាត់ គឺ ៥២៦២រៀល ដែលគិតបញ្ចូលទាំងចំណាយលើម្ហូបអាហារ ៣៨៤៦រៀលផង។ ក្នុងចំណោមអ្នករើសអេតចាយឆ្លើយសម្ភាសន៍ មាន ២៥% បានធ្វើចំណាកស្រុកមកក្រុងភ្នំពេញ ឬខេត្តសៀមរាប តែឯង និង ៧៥% ទៀតមកជាមួយគ្រួសាររបស់គាត់។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់ កម្មកររោងចក្រកាត់ដេរ កើន ៤,៩% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១១។ មុនពេលចូលធ្វើការក្នុងអាជីពបច្ចុប្បន្ន ពួកគាត់ ៧,៥% បានទៅទទួលការបណ្តុះបណ្តាលពីឯកជន ១១,៧% បានទទួលការបណ្តុះបណ្តាលនៅផ្ទះ និង ៥២,៥% បានទទួលការបណ្តុះបណ្តាលក្នុងរោងចក្រ រីឯ ២៨,៣% ទៀតមិនទាន់មានជំនាញទេ។ ពួកគាត់ចំណាយអស់ ៤១៥៤រៀល លើអាហារប្រចាំថ្ងៃ ហើយក្នុង ៣ខែចុងក្រោយនេះ អាចសន្សំប្រាក់បាន ១៦១.៧៩៧រៀល។ ពួកគាត់ ៤៨% ជាសមាជិកសហជីពកម្មករ ដែលមាន កម្មករសេរី យុវជនខ្មែរ និង កម្មករកម្ពុជា។ ពួកគាត់ ៨៥% មានទស្សនៈវិជ្ជមានចំពោះរោងចក្របច្ចុប្បន្នរបស់គាត់។ ប្រសិនជារោងចក្រត្រូវបិទទ្វារ ពួកគាត់ ៦៥% នឹងស្វែងរកការងារផ្សេងទៀតនៅក្រុងភ្នំពេញ ៣១% ត្រឡប់ទៅភូមិស្រុកវិញ និង ៤% មិនដឹងថាត្រូវធ្វើយ៉ាងណាទេ។

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៦-១២*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | | |
| កសិកម្ម | 498.0 | 135.6 | 92.0 | 615.0 | 530.68 | 4.1 | 156.4 | 123.9 | 440.6 | 154.7 | 81.2 | 167.1 |
| ឧស្សាហកម្ម | 365.3 | 709.1 | 724.9 | 818.5 | 403.66 | 67.1 | 257.1 | 2361.0 | 174.9 | 208.7 | 173.7 | 259.5 |
| *កាត់ដេរ* | *89.4* | *170.7* | *142.8* | *90.1* | *122.81* | *57.1* | *108.4* | *109.7* | *118.7* | *139.4* | *97.5* | *107.2* |
| សេវាកម្ម | 2939.1 | 1742.5 | 10,003.2 | 4432.0 | 1337.34 | 209.5 | 2229.2 | 264.1 | 722.6 | 50.9 | 18.0 | 2.1 |
| *សណ្ឋាគារ និងទេសចរណ៍* | *345.0* | *1048.3* | *8758.1* | *3980.1* | *1105.14* | *107.9* | *2221.9* | *264.1* | *257.0* | *50.9* | *0.0* | *0.0* |
| សរុប | 3802.4 | 2587.2 | 10,570.9 | 5865.5 | 2271.7 | 280.72 | 2642.7 | 2748.9 | 1338.1 | 414.4 | 273.0 | 428.8 |
| បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | | |
| សរុប | - | - | - | - | | -77 | 8.41 | -4 | -51.3 | -69 | -33.9 | 55.6 |
| បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | | |
| សរុប | 246.6 | -32 | 308.6 | -44.5 | -61.3 | -24.8 | 643.2 | 753 | 9.6 | 48.4 | -89.6 | -84.4 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៦-១២

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| លានដុល្លារ | | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 33.1 | 79.1 | 154.7 | 64.3 | 36.2 | 4.1 | 5.9 | 106.3 | 60.9 | 64.8 | 66.6 | 18.3 |
| ផ្ទះល្វែង | 213.3 | 297.2 | 221.6 | 149.6 | 183.8 | 16.1 | 22.8 | 90.0 | 58.5 | 60.8 | 219.3 | 61.6 |
| ផ្សេងៗ | 76.8 | 259.6 | 740.9 | 227.3 | 269.7 | 23.6 | 48.7 | 51.1 | 29.3 | 197.2 | 47.8 | 94.9 |
| សរុប | 323.3 | 635.8 | 1117.0 | 441.2 | 489.8 | 43.8 | 77.4 | 247.4 | 148.7 | 322.8 | 333.6 | 174.9 |
| បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 76.7 | 219.7 | -39.9 | 117.1 | 3.3 | -47.6 |
| បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | | |
| សរុប | -9.9 | 96.7 | 75.7 | -60.5 | 11 | -14.8 | -61.7 | 215.6 | 40.29 | 637.1 | 331.1 | -29.3 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៦-១២

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | | |
| តាមផ្លូវអាកាស | 1029.0 | 1296.5 | 1239.4 | 1111.7 | 1304.3 | 427.4 | 286.9 | 335.3 | 430.7 | 513.6 | 317.1 | 370.5 |
| តាមផ្លូវគោក និងទឹក | 672.9 | 718.6 | 881.9 | 999.7 | 1094.6 | 351.0 | 319.6 | 364.5 | 366.3 | 481.5 | 424.3 | 450.3 |
| សរុប | 1701.9 | 2015.1 | 2121.3 | 2111.5 | 2398.9 | 778.4 | 606.5 | 699.8 | 797.1 | 995.2 | 761.4 | 820.9 |
| បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | | |
| សរុប | - | - | - | - | - | 10.4 | -22.1 | 15.4 | 13.9 | 24.9 | -23.5 | 7.8 |
| បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | | |
| សរុប | 19.7 | 28.4 | 5.3 | 0.5 | 13.6 | 13.9 | 12.8 | 20.2 | 13.0 | 27.8 | 25.5 | 17.3 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៦-១២

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| លានដុល្លារ | | | | | | | | | | | | |
| ការនាំចេញសរុប | 2810.9 | 3050.3 | 3097.8 | 2901.6 | 3630.2 | 1017.7 | 1132 | 1455.6 | 1324.2 | 1280.1 | 1775.9 | 1595.8 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2698.8 | 2938.9 | 2986.2 | 2565.3 | 3223.4 | 880.48 | 964.15 | 1285.71 | 1129.23 | 1070.8 | 1474.7 | 1329.1 |
| *- សហរដ្ឋអាមេរិក* | 1847.2 | 1956.5 | 1908.3 | 1512.6 | 1853.9 | 464.47 | 466.7 | 619.38 | 504.71 | 493.3 | 627.3 | 566.6 |
| *- សហភាពអឺរ៉ុប* | 601.0 | 654.3 | 689.0 | 644.7 | 809.5 | 232.0 | 301.4 | 397.5 | 391.3 | 328.4 | 504.1 | 462.7 |
| *- អាស៊ាន* | 2.6 | 3.2 | 10.76 | 6.9 | 9.9 | 3.77 | 4.18 | 4.73 | 4.95 | 6.4 | 11.7 | 11.4 |
| *- ជប៉ុន* | 29.4 | 28.5 | 25.2 | 44.5 | 86.5 | 34.3 | 28 | 43.4 | 41.25 | 50.1 | 48.9 | 47.1 |
| *- ប្រទេសផ្សេងៗ* | 218.7 | 296.4 | 352.9 | 356.5 | 463.6 | 145.9 | 163.89 | 220.68 | 187.03 | 192.5 | 282.7 | 241.3 |
| កសិកម្ម | 59.7 | 55.7 | 44.5 | 73.1 | 164.9 | 74.01 | 97.07 | 98.91 | 92.06 | 80.5 | 101.3 | 86.1 |
| *- កៅស៊ូ* | 41.5 | 41.0 | 35.8 | 51.6 | 89.1 | 49.86 | 48.6 | 56.11 | 43.06 | 40.3 | 46.4 | 46.1 |
| *- ឈើ* | 8.6 | 8.7 | 3.4 | 3.5 | 34.1 | 6.2 | 16.8 | 16.1 | 9.7 | 8.9 | 12.4 | 4.1 |
| *- ត្រី* | 6.0 | 3.2 | 2.3 | 3.9 | 2.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 | 0.7 | 0.4 |
| *- ស្រូវ* | 2.5 | 1.5 | 2.6 | 10.9 | 34.7 | 16.9 | 30.3 | 22.4 | 37.0 | 27.137.5 | | 31.7 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 1.2 | 0.5 | 3.0 | 4.1 | 0.5 | 1.0 | 2.9 | 1.6 | 3.9 | 4.4 | 3.9 |
| ផ្សេងៗ | 52.33 | 55.8 | 67.1 | 263.22 | 242.0 | 63.2 | 70.8 | 71.0 | 102.9 | 128.8 | 199.9 | 180.6 |
| ការនាំចូលសរុប | 3047.9 | 3770.2 | 4272.5 | 4331.5 | 5190.6 | 1454.9 | 1690.1 | 1519.1 | 1711.9 | 1609.2 | 1885.4 | 2015.2 |
| ក្នុងនេះ៖ សាំង | 49.4 | 73.6 | 84.8 | 91.13 | 108.6 | 62.2 | 76.7 | 73.8 | 81.8 | 70.7 | 76.7 | 78.0 |
| ម៉ាស៊ីត | 121.6 | 133.7 | 119.5 | 180.67 | 203.8 | 92.7 | 129.9 | 118.9 | 105.5 | 139.4 | 126.6 | 138.3 |
| សម្ភារៈសំណង់ | 33.8 | 44.31 | 56.3 | 49.74 | 57.6 | 11.8 | 12.7 | 11.6 | 12.0 | 13.5 | 14.1 | 16.5 |
| ផ្សេងៗ | 2843.1 | 3518.5 | 4011.8 | 4010 | 4820.6 | 1288 | 1471 | 1315 | 1513 | 1386 | 1668.0 | 1782.4 |
| ជញ្ជីងពាណិជ្ជកម្ម | -237.0 | -719.9 | -1174.7 | -1429.9 | -1560.5 | -437.2 | -558.1 | -63.5 | -387.6 | -329.1 | -642.2 | -419.4 |
| បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | -6.6 | 9.5 | 33.4 | -12.2 | -5.2 | -37.7 | -9.9 |
| ការនាំចេញសរុប | - | - | - | - | - | -4.9 | 11.2 | 28.6 | -9.0 | -3.3 | 38.7 | -10.1 |
| ការនាំចូលសរុប | - | - | - | - | - | 8.9 | 16.2 | -10.1 | 12.7 | -6.0 | 17.2 | 6.9 |
| បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 19.8 | 8.9 | 1.6 | -14.1 | 25.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 | 53.0 | 3.4 |
| ការនាំចេញសរុប | 19.5 | 8.5 | 1.6 | -6.3 | 25.1 | 46.7 | 37.9 | 39.3 | 23.7 | 25.8 | 56.9 | 9.6 |
| ការនាំចូលសរុប | 21.5 | 23.7 | 13.3 | 1.4 | 19.8 | 30.1 | 33.7 | 3.2 | 28.1 | 10.6 | 11.6 | 32.7 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៦-១២ (ពាន់លានរៀល)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 3259.2 | 1146.1 | 5290.0 | 5988.99 | 2805.83 | 1400.46 | 1564.25 | 1510.1 | 1776.61 | 1728.9 | 2045.1 | 1900.8 |
| ចំណូលចរន្ត | 2881.8 | 1141.6 | 5210.7 | 5859.08 | 2786.12 | 1378.61 | 1563.01 | 1497.59 | 1740.12 | 1725.8 | 1928.6 | 1796.4 |
| ចំណូលពន្ធ | 2270.9 | 965.2 | 4409.9 | 4692.96 | 2457.02 | 1142.29 | 1367.52 | 1313.35 | 1454.33 | 1403.82 | 1721.8 | 1560.7 |
| ពន្ធក្នុងស្រុក | - | 661.8 | 3248.4 | 3533.57 | 1727.10 | 875.569 | 1095.26 | 996.642 | 1104.12 | 1092.27 | 1403.4 | 1230.0 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | 303.5 | 1161.5 | 1159.39 | 639.00 | 266.719 | 272.27 | 316.709 | 350.207 | 311.253 | 318.4 | 330.7 |
| ចំណូលមិនមែនពន្ធ | 610.9 | 176.4 | 800.8 | 1166.13 | 507.13 | 236.329 | 195.48 | 184.23 | 285.8 | 330.98 | 206.9 | 235.7 |
| ចំណូលលើទ្រព្យសម្បត្តិ | - | 13.6 | 78.0 | 291.13 | 4.87 | 10.6426 | 18.64 | 15.19 | 19.35 | 91.28 | 13.1 | 22.5 |
| លក់ទំនិញ និងសេវា | - | 124.3 | 424.7 | 460.07 | 268.08 | 129.982 | 138.92 | 144.192 | 175.627 | 166.899 | 171.4 | 132.8 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | 38.5 | 298.2 | 408.91 | 391.70 | 95.7053 | 37.9 | 24.856 | 90.815 | 63.8 | 22.4 | 80.5 |
| ចំណូលជាមូលធន | 377.4 | 4.5 | 79.3 | 129.92 | 2019.39 | 21.8524 | 1.25 | 12.513 | 36.486 | 3.148 | 116.4 | 104.4 |
| ចំណាយសរុប | 4174.7 | 1689.7 | 6297.8 | 8784.65 | 4259.67 | 1581.62 | 2025.15 | 2310.61 | 3115.05 | 1688.33 | 2425.6 | 2951.3 |
| ចំណាយជាមូលធន | 1638.1 | 807.4 | 2574.4 | 2853.23 | 1495.19 | 579.818 | 721.01 | 801.167 | 1444.89 | 699.937 | 716.2 | 1194.5 |
| ចំណាយចរន្ត | 2536.8 | 882.3 | 3809.0 | 4773.07 | 2848.81 | 857.492 | 1304.13 | 1509.44 | 1670.15 | 988.398 | 1709.4 | 1756.7 |
| បៀវត្សរ៍ | 822.0 | 362.6 | 1397.0 | 2048.81 | 1208.81 | 401.0 | 531.6 | 629.697 | 608.253 | 508.919 | 725.2 | 657.5 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | 194.2 | 927.1 | 1099.42 | 613.31 | 257.356 | 450.85 | 323.282 | 487.345 | 189.594 | 514.6 | 462.1 |
| ចំណាយចរន្តផ្សេងទៀត | - | 325.5 | 1384.9 | 1624.84 | 1067.07 | 199.1 | 321.7 | 556.5 | 574.6 | 289.9 | 469.7 | 637.1 |
| សមតុល្យជាទូទៅ | -915.5 | -543.6 | -1007.8 | -2795.66 | -1453.83 | -181.2 | -460.9 | -800.5 | -1,338.4 | 196.5 | -380.6 | -1050.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1360.7 | 741.5 | 2055.10 | 1845.21 | 772.81 | 544.4 | 576.9 | 272.9 | 985.0 | 577.8 | 491.5 | 959.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -445.1 | -185.8 | -127.00 | 938.64 | 567.96 | -1,745.2 | 238.7 | 312.5 | 105.6 | -565.7 | 148.4 | 22.1 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៦-១២

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.7 | 5.8 | 19.7 | -0.7 | 4.1 | 3.6 | 6.3 | 6.7 | 4.9 | 2.9 | 2.9 | 1.6 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 9.9 | 33.1 | -0.3 | 4.4 | 3.9 | 7.6 | 8.2 | 6.2 | 3.4 | 3.4 | 1.3 |
| - ដឹកជញ្ជូន | 9.1 | 5.8 | 19.4 | -10.7 | 7.0 | 5.0 | 7.3 | 8.8 | 6.3 | 3.0 | 3.0 | 1.1 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.0 | 4062.7 | 4058.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.7 |
| រៀលក្នុង ១ បាតថៃ | 108.7 | 122.8 | 123.5 | 121.1 | 133.13 | 132.7 | 133.8 | 135.2 | 131.1 | 130.2 | 129.0 | 129.3 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.1 | 25.0 | 24.8 | 23.4 | 21.725 | 19.9 | 19.6 | 19.8 | 19.4 | 19.3 | 19.4 | 19.5 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 70.6 | 83.2 | 105.9 | 113.1 | 147.58 | 147.9 | 181.5 | 204.6 | 203.8 | 204.1 | 194.5 | 198.3 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3140.0 | 3262.3 | 4555.2 | 3170.9 | 3859.3 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5193.9 | 4458.3 | 4983.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 4004.0 | 4005.0 | 4750.8 | 3593.1 | 4368.1 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 | 5308.3 | 5251.3 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១២ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,903.0 | 16,697.9 | 17,079.1 | 18,099.9 | 17,695.2 | 17,893.9 | 18,652.3 | 18,729.6 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -282.0 | 576.0 | 1513.3 | 1573.0 | 1984.8 | 2778.9 | 3199.2 | 3907.7 | 4961.6 | 5760.8 | 6211.2 | 7922.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -953.0 | -1816.0 | -2987.0 | -2252.0 | -2120.4 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 | -2542.4 | -2399.9 |
| ឥណទានដល់ផ្នែកឯកជន | 3630.0 | 6386.0 | 9894.0 | 10,532.0 | 12,479.8 | 13,331.2 | 13,909.0 | 15,290.6 | 16,385.7 | 17,552.8 | 18,789.0 | 20,081.4 |
| រូបិយវត្ថុទូទៅ M2 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 18,887.8 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 | 24,863.5 | 26,651.9 |
| រូបិយវត្ថុ M1 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3061.7 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 | 3984.6 | 3871.8 |
| រូបិយវត្ថុផ្សេងៗ | 5285.0 | 9259.0 | 9459.0 | 13,108.0 | 15,826.1 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 | 20,878.9 | 22,780.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 38.1 | 62.9 | 4.8 | 36.9 | 26.7 | 20.0 | 17.7 | 20.5 | 20.0 | 21.5 | 20.2 | 21.1 |
| រូបិយវត្ថុ M1 | 25.3 | 23.8 | 16.9 | 30.1 | 10.4 | 3.2 | 11.1 | 13.6 | 20.2 | 22.8 | 11.4 | 9.4 |
| រូបិយវត្ថុផ្សេងៗ | 42.8 | 75.2 | 2.2 | 38.6 | 30.4 | 24.0 | 19.1 | 21.9 | 19.9 | 21.2 | 22.0 | 23.4 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2012 | | |
| | | | | | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 8075 | 12,628 | 8091 | 9055 | 9348 | 9380 | 10,686 | 10,690 | 10,454 | 29.9 | 8.6 | 12.5 |
| អ្នកលីសែង | 8588 | 9005 | 9549 | 9964 | 11,554 | 10,804 | 12,713 | 12,479 | 12,574 | 27.9 | 18.5 | 9.4 |
| អ្នកលក់បន្លែតូចតាច | 8220 | 9926 | 8273 | 8266 | 7116 | 12,292 | 9,901 | 10,347 | 10542 | 14.2 | 22.4 | 49.0 |
| អ្នករើសអេតចាយ | 5422 | 4652 | 5857 | 6698 | 10,347 | 7986 | 8266 | 9139 | 9328 | -5.3 | 20.2 | -9.3 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4482 | 4327 | 4646 | 5607 | 6271 | 6179 | 6261 | 5569 | 6436 | 2.4 | 2.3 | 3.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 8697 | 6197 | 5691 | 4577 | 4690 | 6431 | 8483 | 5000 | 6.6 | 14.8 | 9.9 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 6554 | 7085 | 7746 | 8620 | 8555 | 8391 | 9599 | 8989 | 4.7 | 9.8 | 4.9 |
| អ្នករត់ម៉ូតូឌុប | 10,634 | 15,691 | 10,685 | 10,623 | 12,971 | 12,256 | 13,616 | 12,807 | 13,042 | 27.1 | 14.2 | 1.1 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 8779 | 8343 | 8790 | 9914 | 10,658 | 11,589 | 10,690 | 11,375 | 22.1 | 1.0 | 15.4 |
| កម្មករសំណង់មានជំនាញ | 11,154 | 12,710 | 12,487 | 11,952 | 15,013 | 13,824 | 12,847 | 14,029 | 14,270 | 3.1 | 10.0 | -4.4 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000. Source: CDRI*